**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ......សហវ.

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការដាក់ឱ្យអនុវត្តអង្គភាពថវិកា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨៨៨អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៨២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងដាក់អោយអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៥៩៩សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅស្ថាប័នចំនួន១១ នៅឆ្នាំ ២០១៧
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងផែនការ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

- ប្រការ១

ទទួលស្គាល់ និងដាក់អោយអនុវត្តអង្គភាពថវិកាចំនួន ២៩ (០៤ រដ្ឋបាលកណ្តាល និង ២៥ រាជធានី-ខេត្ត) ដូចខាងក្រោម៖

១. អគ្គនាយកដ្ឋានផែនការ

២. វិទ្យាស្ថានជាតិស្ថិតិ

៣. អគ្គលេខាធិការដ្ឋានប្រជាជន និងអភិវឌ្ឍន៍

៤. អគ្គនាយកដ្ឋានកិច្ចការទូទៅ

៥. មន្ទីរផែនការ រាជធានី-ខេត្ត ទាំង២៥

- **ប្រការ២**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

- **ប្រការ៣៖**

នាយកខុទ្ទកាល័យ អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
  នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចប្រការ១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ